**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង រវាង

# នៃក្រុមហ៊ុន ផាភីលៀន ថេកស្លាយ (ខេមបូឌា)ខូអិលធីឌី

# និង

# ប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព និងប្រធានក្រុមគ្រប់ផ្នែក

# នៃក្រុមហ៊ុន ផាភីលៀន ថេកស្លាយ (ខេមបូឌា)ខូអិលធីឌី

# ស្តីពី

# ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ

# ដោយរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារបញ្ហាកង្វះវត្ថុធាតុដើម និងមិនមានអ្នកបញ្ជាទិញ

ឆ្នាំពីរពាន់ម្ភៃបី ខែមិថុនាថ្ងៃទី២៣ វេលាម៉ោង ១៥:០០ រសៀល នៅក្នុងការិយាល័យរដ្ឋបាលក្រុមហ៊ុន ផាភីលៀន ថេកស្លាយ(ខេមបូឌា)ខូអិលធីឌី ដែលមានអាស្រ័យដ្ឋានស្ថិតនៅផ្លូវជាតិលេខ៣ ភូមិព្រៃសំព័រ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ បានរៀបចំការប្រជុំមួយរវាងក្រុមហ៊ុន ផាភីលៀន ថេកស្លាយ(ខេមបូឌា)ខូអិលធីឌី និងប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព ប្រធានក្រុមគ្រប់ផ្នែកប្រចាំក្រុមហ៊ុន។

ក្នុងអង្គប្រជុំ ប្រធានផ្នែករដ្ឋបាល បានមានមតិស្វាគមន៍ និងសំណេះសំណាលជាមួយបងប្អូនប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព និងប្រធានក្រុមគ្រប់ផ្នែក ក្នុងអង្គប្រជុំនោះផងដែរ ប្រធានផ្នែករដ្ឋបាលបានជម្រាបជូនតំណឹងដល់បងប្អូនប្រតិភូបុគ្គលិក (តំណាងកម្មករ) និងតំណាងសហជីព ប្រធានក្រុមគ្រប់ផ្នែកទាំងអស់ អំពីស្ថានភាពបច្ចុប្បន្នដែលប្រឈមមុខយ៉ាងខ្លាំងនូវបញ្ហាកង្វះវត្ថុធាតុដើម និងមិនទាន់មានអ្នកបញ្ជាទិញ ដែលជាមូលហេតុធ្វើអោយសង្វាក់ផលិតកម្មមិនអាចដំណើរការឲ្យបងប្អូនកម្មករនិយោជិតបានធ្វើការងារពេញលេញឡើយ។ ហេតុដូចច្នេះថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនបានសម្រេចចិត្តព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសរុបចំនួន ....២៨៣...នាក់ ស្រី...២៥៤...នាក់ ក្នុងចំណោមកម្មករសរុប...១១៩៧..នាក់ រយៈពេល ២៨ ថ្ងៃ គឺចាប់ពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២៣ និងចូលមកធ្វើការវិញនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២៣ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ បងប្អូនកម្មករនិយោជិតបានយល់ព្រម និងឯកភាពទទួលយកប្រាក់ឧបត្ថម្ភរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌដូចខាងក្រោម៖

១.ភាគីក្រុមហ៊ុន ឯកភាពផ្តល់ប្រាក់ឧបត្ថម្ភចំនួន $៣០ (សាមសិបដុល្លា) ក្នុងកំឡុងពេលព្យួរ និងកំណត់បើកជូនបងប្អូនកម្មករនិយោជិតនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣។

កិច្ចប្រជុំនេះ បានបញ្ចប់នៅវេលាម៉ោង ១៥:៣០ រសៀលនាថ្ងៃខែឆ្នាំដដែល ក្រោមកិច្ចព្រមព្រៀងគ្នាដោយស្មារតីយោគយល់គ្នា សហការគ្នា និងការទទួលខុសត្រូវខ្ពស់បំផុត។

ថ្ងៃពុធ ៦កើត ខែប.សាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២៣

**ហត្ថលេខា និងត្រានាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ផាភីលៀន ថេកស្លាយ (ខេមបូឌា) PAPILLION TEXTILE (CAMBODIA) CO., LTD. ក្រសួងពាណិជ្ជកម្ម រាជធានីភ្នំពេញ

LIEU VILUAN

## ស្នាមមេដៃ ប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព

១.លោកស្រី ណាន ឡុន

២. លោកស្រី រុន សំភី

៣.លោកស្រី វែង សុខា

៤.លោក គូ គាំ

៥.លោកស្រី សាន សុខលី

៦.លោកស្រី ហូ ស៊ីណាង

៧.លោក ផល ស្តើង

៨. លោកស្រី ភួង ផល្លី

៩. លោកស្រី ផល ចន្ទី

១០.លោក សែម សារ៉ូត

១១.អ្នកនាង ឡុញ ចាន់ថា

១២.លោកស្រី ឡុញ វន្នី

១៣.លោក គង់ សោភ័ណ្ឌ

១៤.លោក រិន កុយ

១៥.អ្នកនាង អោម មិន

១៦.អ្នកនាង ផែន អូន

១៧.អ្នកនាង យ៉ុង កញ្ញា

១៨.អ្នកនាង អៀត សារូ